# រឿង មហាចោរនៅទល់ដែន

## ភាគទី៨ រាត្រីស្ងាត់

- លោកឪពុក កូនសូមទោស! ចា៎ះ! កូនសូមទោស លោកឪពុក! កូនបានជាខុសចំពោះចិត្តលោកឪពុកហើយ។ ចា៎ះ! កូនខុសពិតមែន។ កូនស្រលាញ់ ។ កូនបានលបចេញពីផ្ទះទៅជួបនឹងគេទាំងយប់ពាក់កន្ដាលអធ្រាត្រ។ កូនខុសនឹងទំនៀមទំលាប់ ខុសនឹងអ្នកមានគុណមែនហើយ។ តែសូមលោកឪពុកជ្រាបថាកូនពុំទាន់បានខុសនឹងធម្មជាតិទេ។ កូនជាផ្នែកមួយរបស់ធម្មជាតិ កូនជាមនុស្ស។

ថាហើយនាងមើលមុខវិសេសក្វាហាន។ តែទឹកមុខបិតានៅក្រហមដដែល ភ្នែកនៅតែសម្លក់ក្រឡោតដដែល មានតែថ្គាមទាំងពីរ ដែលប្រខាំគ្នាថែមទៀត នារីអស់សង្ឃឹម។ ញើសលោតចេញពីថ្ងាសនាងផ្អោត។ ហូរតាមខ្នងនាង។ ស្ងួនភ្ងាដឹងថា ឪពុកនាងពុំប្រណីទោសនាងទេ។ ហេតុនេះមានតែទឹកភ្នែកប៉ុណ្ណោះ ដែលនិយាយទៅទៀត។

វិសេសក្វាហានក្រោកឈរឡើង ដង្ហើមធំៗ ខ្ញីៗ មុខដូចខ្លា។ នាងទេវីរិតតែភ័យទៅទៀតឱបជើងលោកឪពុក។ នាងក្លួងអោជើងម្ខាង។ យូរបន្តិចមក វិសេសក្វាហានអោនទៅចាប់បុត្រីឲ្យក្រោកឈរឡើង នាងទេវីបានធូរក្នុងចិត្តឥតឧបមា នឹកថាឪពុកនាងយល់ព្រមអនុលោមកំហុសនាងហើយ។ វិសេសក្វាហានដឹកដៃធោមស្ងួនទៅមាត់ទ្វារ។ កញ្ញាបែរជាធ្ងល់ឡើងវិញជាពន់ពេក ដោយមិនដឹងថា ឪពុកនាងចង់ធ្វើយ៉ាងណា ចង់និយាយយ៉ាងណា។ លុះដល់មាត់ទ្វារហើយ វិសេសក្វាហានច្រានស្នានាងទេវីយ៉ាងខ្លាំងទៅខាងក្រៅ ដោយពន្ទឺពាក្យថា៖

- ទៅចុះ អញអស់មានកូនទៀតហើយ។

នាងក្លួងដែលឃើញរឿងចំលែកអស្ចារ្យដូច្នោះ ស្ទុះក្វេតទៅឱបជើងវិសេសក្វាហានសាជាថ្មី ហៀបនឹងនិយាយ តែវិសេសក្វាហានច្រាននាងដួលទៅក្រោយដោយគំហកថា៖

- ទេ! អញគ្មានកូនទៀតទេ។

អត្ថបទដោយ៖ មាស សុភាព

នៅខាងក្រៅ នាងទេវីឱបដៃស្រពោនដូចផ្កាត្រូវថ្ងៃ។ នាងអស់ចិត្ត អស់ពាក្យនឹងនិយាយ អស់គំនិតនឹងគិត។ ស្រីយំខះទឹកភ្នែកអស់ហើយ។ មួយរំពេចនេះ នាងឃើញជាក់ថាកែវអស់ផ្ទះនៅទៀតហើយ គឺមុខជាដេកក្រោមដើមឈើ ត្រូវខ្យល់ ត្រូវថ្ងៃ ត្រូវភ្លៀង អត់បាយហើយ ចាប់ពីរាត្រីនេះតទៅ។ ទេវីបែរមើលក្នុងទីងងឹត ដើម្បីរកផ្លូវដែលនាងត្រូវដើរទៅមុខក្នុងជីវិតនេះ តែមិនឃើញផ្លូវណាសោះ។កល្យាណបែរមើលរកទិសដែលនាងត្រូវយក តែមិនដឹងជាយកទិសណាសោះ។ នាងបែរមើលដំបូលផ្ទះ។ ឱ! ដំបូលនេះដាច់ចិត្តលែងទទួលនាងទៅហើយ។

មាននន្ទមកដល់ ! ដៃប្រុសម្នាក់ចាប់នាងយ៉ាងខ្លាំងទាញចូលក្នុងផ្ទះវិញ។ ជីតាភ្ញាក់។ មាននន្ទដើរយ៉ាងស្វាហាប់ចូលស្ទុងទៅក្នុងផ្ទះ លុតជង្គង់ម្ខាងគ្រឹប ទៅលើក្តារពីមុខវិសេសក្លាហាន និយាយដោយវាចាមួយៗ យ៉ាងដាច់ខាត៖

- សូមទានលោកអ៊ំ រូបកូនប្រុសរបស់លោកអ៊ំ ទើបលេចចេញពីបន្ទូលចិត្តលោកអ៊ំ។ ខ្ញុំមាននន្ទ ខ្ញុំសូមប្រគល់ខ្លួន ប្រគល់ជីវិតជាកូនប្រុសតែមួយរបស់លោកអ៊ំ។ សូមលោកអ៊ំជឿថា កូនប្រុសនេះមានចិត្តដូចលោក មានគំនិតដូចលោកអ៊ំ មានឧត្តមគតិចំពោះជាតិ និងចំពោះប្រជាជនដូចលោកអ៊ំគ្មានខុសប៉ុនមួយចម្រៀកសក់ទេ។ ខ្ញុំសូមលើកដៃសច្ចាចំពោះមុខលោកអ៊ំថា ចាប់តាំងពីយប់នេះទៅ ខ្ញុំធ្វើការពុះពារគ្រប់បែបយ៉ាងប្រឆាំងនឹងអយុត្តិធម៌ ដែលជនជាតិខ្មែរយើងកំពុងរងទុក្ខវេទនា ប្រឆាំងនឹងគំនិតខ្ញុំគេដែលខ្មែរមានប្រឆាំងនឹងជនជាតិនានា ដែលគ្របសង្កត់ខ្មែរយើងជំនួសលោកអ៊ំដែលចាស់ណាស់ទៅហើយ។ ក្នុងការតស៊ូនេះ ខ្ញុំប្តេជ្ញាជាឱឡារិកថា ចំពោះប្អូនទេវីខ្ញុំទទួលបីបាច់រក្សាអស់មួយជីវិត ទុកនាងជាគូវាសនាពីអតីតជាតិមក ហើយជាវត្ថុមួយដ៏ថ្លៃថ្លា ដែលខ្ញុំការពាររាល់ទិវា។

វិសេសក្លាហាន មើលមុខមាននន្ទដោយពុំលែងចោលសោះ។ លោកញញឹមជាសញ្ញាទទួលយល់ព្រម។ លោកងក់ក្បាល រួចលូកដៃទៅចាប់ស្មាមាននន្ទ មានវាចាថា៖

- ចាប់តាំងពីពេលនេះតទៅ ឯងជាកូនអញទាំងពីរ។

អត្ថបទដោយ៖ មាស សុភាព

នាងទេវីសប្បាយចិត្តក្នុងគ្រានោះ នឹងរកវត្ថុអ្វីមកប្រៀបគ្មានឡើយ។ នាងហាក់ហើបខ្លួនពីដី ហាក់អណ្តែតត្រសែតលើអាកាសជាមួយមានន្ទ និងជាមួយឪពុកនាង កញ្ញាស្ទុះទៅឱបជង្គង់លោកឪពុកជាទីស្នេហា។ នាងក្លងក៏ធ្វើដូច្នោះដែរ។ វិសេសក្វាហានបន្តសេចក្តីមួយៗដូចតទៅ ៖

- កាលណាបានឯងគិតរៀបការគ្នា ?
- បាទខ្ញុំបាទសូមរៀបការក្នុងបីខែទៀត។

វិសេសក្វាហានងើបទៅលើគិត។ រួចលោកគ្រវីក្បាល។

- ទេ ! មិនបានទេ
- បាទពីរខែទៀត
- ទេ!
- បាទមួយខែទៀត
- ទេ !
- បើដូច្នោះតាមចិត្តលោកអ៊ំកាលណា ? មួយអាទិត្យទៀត ?
- ទេ ! មិនបានទេ។ តោងសែនទាំងយប់នេះ។

មានន្ទឮដូច្នោះ ក៏ដាក់ភ្នែកចុះ។ អ្នកនៅស្មៀមគិតវាយក្រឡាស្មង់ ញញឹមរួចទទួល :

- បាទ ! បាន !

ពិធីសែនព្រេនចាប់ធ្វើឡើងមួយរំពេចក្នុងវេលានោះ។ នាងក្លងត្រូវទៅដាស់លោកមេឃុំជំទប់មកដោយឥតបង្អង់។ នាងទេវីត្រូវធ្វើម្ហូបអាហារមាន់ទាសំរាប់សែនក្វាម។ វិសេសក្វាហាន និងមានន្ទត្រូវកាច់ស្វាធម៌ រកទៀនធូបដោយរួសរាន់។ មិនយូរប៉ុន្មាន លោកមេឃុំលោកជំទប់ក៏មកដល់ ភ្លើងទៀនធូបក៏ភ្លឺរន្ទាល កូនស្រី កូនប្រុសក៏ក្រាបទាំងគូទន្ទឹមគ្នា។

**(សូមរង់ចាំតាមដានភាគទី៩ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព